# សារលិខិតរបស់សម្តេចប៉ាប
# បេណេឌិកទី ១៦
# ចំពោះយុវជនក្មេងៗ ទូទាំងពិភពលោក
# ក្នុងឱកាស
# ទិវាយុវជនពិភពលោក ទី ២៣ ឆ្នាំ ២០០៨

**"អ្នករាល់គ្នានឹងទទួលនូវអំណាចនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលយាងមកក្នុងចំណោមអ្នករាល់គ្នា ហើយអ្នករាល់គ្នា ជាសក្ខីភាពរបស់ខ្ញុំ" (កិច្ចការ ១ : ៨)**

កូនៗយុវជនជាទីស្រឡាញ់!

**១. ទិវាយុវជនពិភពលោក ទី ២៣ :**

ខ្ញុំតែងតែចងចាំជានិច្ចនូវអំណរសប្បាយនាឱកាសដែលយើងចំណាយពេលជួបជុំគ្នានៅ **Cologne** ក្នុងខែសីហា ឆ្នាំ ២០០៥។ ក្នុងថ្ងៃបញ្ចប់ទិវាយុវជនពិភពលោក ខ្ញុំមានមោទនភាពនិងរីករាយជាខ្លាំងចំពោះបងប្អូនដែលប្រកាសជំនឿចំពោះព្រះជាម្ចាស់ដែលខ្ញុំចាំទុកក្នុងចិត្តនិងវិញ្ញាណខ្ញុំរៀងរហូតមក។ ខ្ញុំបានប្រកាសជាឱឡារិកនៅពេលនោះថាទិវាយុវជនពិភពលោកលើកទី XXIII ឆ្នាំ ២០០៨ និងប្រារព្ធឡើងនៅស៊ីដនីនោះគ្រប់ៗគ្នានឹងបានទទួលព្រះ ពរ "អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលយាងមកក្នុងចំណោមអ្នករាល់គ្នា ហើយអ្នករាល់គ្នាជាសក្ខីភាពរបស់ខ្ញុំ" (កិច្ចការ ១ : ៨)។ ទិវាយុវជននៅស៊ីដនីនេះនឹងប្រព្រឹត្តទៅតាមរយៈការបំភ្លឺពីព្រះវិញ្ញាណដ៏វិសុទ្ធមានលក្ខណៈជាបេសកកម្ម។ ឆ្នាំ ២០០៦ ជាឆ្នាំដែលព្រះវិញ្ញាណដ៏វិសុទ្ធជាសេចក្តីពិត។ ឥឡូវនេះឆ្នាំ ២០០៧ យើងនឹងពិចារណាអោយស៊ីជម្រៅថែមទៀត ដែលព្រះវិញ្ញាណដ៏វិសុទ្ធជាសេចក្តីស្រឡាញ់។ យើងនឹងត្រៀមលក្ខណៈសព្វបែបយ៉ាងឆ្ពោះទៅ WYD ២០០៨ ដោយចែកបទពិសោធន៍តាមរយៈការតស៊ូ និងសក្ខីភាពលើកទឹកចិត្តយើងអោយរស់នៅជាមួយព្រះបន្ទូលនិងសេចក្តីក្លាហានក្នុងការប្រកាសដំណឹងល្អ។ ដូច្នេះវាជារឿងសំខាន់ដែលយុវជនម្នាក់ៗរួមជាមួយសហគមន៍របស់ពួកគេ រួបរួមគ្នាដើម្បីទទួលខុសត្រូវក្នុងការអប់រំ មិនតែប៉ុណ្ណោះគេត្រូវចែករំលែកព្រះអំណោយទាននៃសេចក្តីសង្រ្គោះរបស់ព្រះជាម្ចាស់ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធនិងព្រះយេស៊ូជាអម្ចាស់។ ធ្វើរបៀបនេះអ្នកនឹងបានទទួលជោគជ័យដ៏ត្រចះត្រចង់ ស្គាល់សេចក្តីពិតដោយប្រតិបត្តិតាមព្រះបន្ទូល ដើម្បីអោយយល់អំពីព្រះគម្រោងការណ៍របស់ព្រះជាម្ចាស់ ហើយឈានទៅរួបរួមគ្នាបំពេញបេសកកម្មក្នុងព្រះសហគមន៍របស់ខ្លួន។ ជាពិសេសជួយយើងអោយកាន់តែដឹងច្បាស់ថា "ព្រះវិញ្ញាណដ៏វិសុទ្ធគង់ជាមួយយើង" ដែលជាដង្ហើមក្នុងជីវិតគ្រីស្ត

បរិស័ទ ។តាមរយៈអត្ថសញ្ញានៃការត្រាស់ហៅ ដូចជាអត្ថសញ្ញាជ្រមុជទឹក ដែលបង្ហាញអំពីការរីកចំរើននៃជំនឿក្នុង អង្គព្រះយេស៊ូគ្រីស្តពេញដោយអំណរសប្បាយ ។ ទន្ទឹមគ្នានេះដែរត្រូវយកព្រះបន្ទូលទុកជាការប្រតិបត្តិនៅសហសវត្សរ៍ ទី ៣ ដែលនឹងមកដល់ ។ ក្នុងសារលិខិតនេះខ្ញុំមានអំណរសប្បាយនឹងការផ្តល់អោយនូវចំណុចដែលត្រូវរិះគិតមួយចំនួន ដើម្បីត្រៀមរៀបចំចូលរួម WYD នេះ ។ ធ្វើរបៀបនេះអ្នកអាច ដឹងអំពីជំនឿរឹងមាំរបស់អ្នកចំពោះព្រះវិញ្ញាណ ដ៏វិសុទ្ធ ហើយរកអោយឃើញនូវចំណុចខ្សោយ ដើម្បីអោយអ្នកបានពេញលេញឡើងវិញតាមរយៈការទូលសូមព្រះ សង្គ្រោះជាព្រះបិតានិងព្រះបុត្រា ដោយដាក់ខ្លួនអោយឋិតក្រោមតេជានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវចងចាំថា ព្រះសហគមន៏ត្រូវការរស់នៅដោយសេចក្តីសប្បុរសជាមួយមនុស្សម្នាដែលនៅជុំវិញអ្នកនិងខ្លួនអ្នក ដែលរង់ចាំអ្នកជួយ ដើម្បីអនាគត ជាពិសេសចំពោះយុវជនក្មេងៗ ពីព្រោះអ្នកជាមនុស្សដែលបានទទួលព្រះអំណោយទានពីព្រះជាម្ចាស់ ។

## ២. ព្រះបន្ទូលសន្យាក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រី :

ចូរស្តាប់ព្រះបន្ទូលដ៏អាថ៌កំបាំងនិងឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបើកដួងចិត្តនិងបំភ្លឺយើងតាមរយៈ ព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់ ។ ដើម្បីរួមគ្នាអធិដ្ឋានជាមួយព្រះនាងព្រហ្មចារីម៉ារី សូមព្រះជាម្ចាស់មេត្តាចាក់ បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធលើព្រះសហគមន៏ដ៏ក្មេងខ្ចីស្របតាមព្រះបន្ទូលសន្យាដែលមានចែងក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់

តាមពិតចាប់តាំងពីទំព័រដំបូងក្នុងព្រះគម្ពីរបានបង្ហាញអំពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដូចជាខ្យល់ "រេរានៅ លើផ្ទៃទឹក" (កំណើតពិភពលោក ១: ២) ។ ក្នុងព្រះគម្ពីរមានចែងថា ព្រះជាម្ចាស់បានយកធូលីដីមកសូនធ្វើជារូប មនុស្ស រួចព្រះអង្គផ្លុំដង្ហើមជីវិតចូលតាមរន្ធច្រមុះគេ មនុស្សក៏មានជីវិតរស់ឡើង (កំណើតពិភពលោក ២:៧) ។ ដោយហេតុនេះមនុស្សទទួលជីវិតរួមជាមួយព្រះអង្គ បន្ទាប់មកមនុស្សក៏ទទួលនូវបាបកំណើតធ្វើអោយជីវិតដែលព្រះ អង្គបានប្រោសប្រទាននោះ កាន់តែសាបសូន្យទៅនៅក្នុងប្រវត្តិរបស់មនុស្សជាតិ ។ ព្រះជាម្ចាស់បានត្រាស់ហៅព្យាការី ដើម្បីណែនាំប្រជារាស្ត្រអោយត្រឡប់មករកព្រះអង្គវិញ ដោយប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអង្គយ៉ាងស្មោះត្រង់ ដូចក្នុងគម្ពីរអេសេគីអែល ព្រះជាម្ចាស់គង់ជាមួយដើម្បីជួយសង្គ្រោះជីវិតជនជាតិអ៊ីស្រាអែល ដូចមានបង្ហាញអំពី "ឆ្អឹងស្ងួត" (អេសេគីអែល ៣៧:១-១៤) ។ ព្យាការីយ៉ូអែលថ្លែងថា "ចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធដល់មនុស្សទាំង អស់ ។ នៅ The secred author "សរសេរថា សូមវិញ្ញាណរបស់ខ្ញុំបានសស្អាត អោយក្លាយជាអ្នកបំរើដ៏ស្មោះត្រង់ រៀងរាល់ថ្ងៃ សូមដុតកំដៅដួងចិត្តខ្ញុំ" (៣ :១-២) ។

ប៉ុន្តែដល់ពេលកំណត់ហើយព្រះជាម្ចាស់ក៏ចាត់ព្រះបុត្រារបស់ព្រះអង្គអោយប្រសូតពីស្ត្រីព្រហ្មចារីម៉ារីអោយ ស្របតាមព្រះវិន័យ (កាឡាទី ៤:៤) ។ ទេវទូតឆ្លើយទៅនាងវិញថា "ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកសណ្ឋិតលើនាង គឺឫទ្ធានុភាពរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត" នឹងគ្របបាំងនាង ។ ហេតុនេះគេនឹងថ្វាយព្រះនាមដល់បុត្រដ៏វិសុទ្ធដែលត្រូវ ប្រសូតមកនោះថា "ព្រះបុត្រារបស់ព្រះជាម្ចាស់" (លូកា ១:៣៥) ។ ក្នុងព្រះគម្ពីរអេសាយ (១:១-២, ៤២:១)... ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នឹងសណ្ឋិតលើព្រះបុត្រានោះ គឺជាព្រះវិញ្ញាណដែលផ្តល់ព្រះប្រាជ្ញាញាណ អោយចេះ ពិចារណាដឹងខុសត្រូវ ព្រះវិញ្ញាណដែលបំភ្លឺអោយស្គាល់និងកោតខ្លាចព្រះជាម្ចាស់ ។ នេះជាព្រះបន្ទូលដែលព្រះយេស៊ូ

យកមកប្រកាសនៅ Synagogue in Nazareth។ ព្រះយេស៊ូមានព្រះបន្ទូលទៅមហាជនថា "ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់សណ្ឋិតលើខ្ញុំ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំ អោយនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ព្រះអង្គបានចាត់ខ្ញុំអោយមកប្រាប់ជនជាប់ជាឈ្លើយថាគេនឹងមានសេរីភាព ហើយអោយប្រាប់មនុស្សខ្វាក់ថា គេនឹងមើលឃើញវិញ។ ព្រះអង្គបានចាត់ខ្ញុំអោយមករំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិន" (លូកា ៤:១៨-១៩ និងអេសាយ ៦១:១-២)។

ព្រះយេស៊ូមានព្រះបន្ទូលថា "ហេតុការណ៍ដែលមានចែងទុកនៅក្នុងព្រះគម្ពីរដែលអ្នករាល់គ្នាទើបនឹងស្តាប់អម្បាញ់មិញ បានសំរេចជារូបរាងនៅថ្ងៃនេះហើយ" (លូកា ៤:២១)។ ខ្ញុំនឹងទូលអង្វរព្រះបិតាហើយព្រះអង្គនឹងប្រទានព្រះសង្គ្រោះមួយអង្គមកគង់ជាមួយអ្នករាល់គ្នាជាដរាបតរៀងទៅ។ ខ្ញុំប្រាប់សេចក្តីទាំងនេះអោយអ្នករាល់គ្នាដឹងក្នុងពេលដែលខ្ញុំស្ថិតនៅជាមួយអ្នករាល់គ្នានៅឡើយ។ រីឯព្រះដ៏ជួយការពារដែលខ្ញុំនឹងចាត់ពីព្រះបិតាអោយមករកអ្នករាល់គ្នា គឺជាព្រះវិញ្ញាណដែលសំដែងសេចក្តីពិតពីព្រះបិតាមក។ កាលណាព្រះអង្គយាងមកដល់ ទ្រង់នឹងធ្វើបន្ទាល់អំពីខ្ញុំ។ កាលណាព្រះវិញ្ញាណនៃសេចក្តីពិតយាងមកដល់ ព្រះអង្គនឹងណែនាំអ្នករាល់គ្នាអោយស្គាល់សេចក្តីពិតគ្រប់ជំពូក ដ្បិតសេចក្តីផ្សេងៗ ដែលព្រះអង្គថ្លែងមិនចេញមកពីព្រះអង្គផ្ទាល់ទេ គឺព្រះអង្គថ្លែងតែសេចក្តីណាដែលទ្រង់ព្រះសណ្តាប់ឮ ព្រមទាំងមានព្រះបន្ទូលអោយអ្នករាល់គ្នាដឹងអំពីហេតុការណ៍ដែលត្រូវកើតមាននៅថ្ងៃមុខផង (យ៉ូហាន ១៤:១៦-១៧, ២៥-២៦, ១៥:២៦, ១៦:១៣)។

**៤. ថ្ងៃដែលព្រះវិញ្ញាណយាងមក គឺជាថ្ងៃចាប់ផ្តើមបេសកកម្មនៃព្រះសហគមន៍ :**

នៅល្ងាចដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានយាងមកគង់កណ្តាលចំណោមសាវ័ករបស់ព្រះអង្គ ព្រះអង្គផ្លុំលើពួកគេទាំងមានព្រះបន្ទូលថា "ចូរទទួលព្រះវិញ្ញាណ!" (យ៉ូហាន ២០:២២)។ ដោយឫទ្ធានុភាពព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកសណ្ឋិតលើក្រុមសាវ័កនៅក្នុងថ្ងៃដែលព្រះវិញ្ញាណយាងមក។ បើយើងអានព្រះគម្ពីរកិច្ចការគ្រីស្តទូត "រំពេចនោះស្រាប់តែមានឮស្នូរសន្ធឹកពីលើមេឃដូចខ្យល់បក់បោកយ៉ាងខ្លាំងពេញក្នុងផ្ទះដែលគេនៅ។ ពួកសាវ័កបានឃើញហាក់ដូចជាអណ្តាតភ្លើងបែកចេញពីគ្នាចុះមកសណ្ឋិតលើពួកគេម្នាក់ៗ" (កិច្ចការ ២:២-៣)។ ព្រះវិញ្ញាណដ៏វិសុទ្ធបានចាក់បង្ហូរលើក្រុមសាវ័កធ្វើអោយពួកគេរឹងមាំ នឹងលើកកម្លាំងចិត្តពួកគេអោយអង់អាចក្នុងការប្រកាសដំណឹងល្អ "ព្រះយេស៊ូសោយទិវង្គតហើយព្រះអង្គមានព្រះជន្មរស់ឡើងវិញ!" ពួកគេបានពោរពេញដោយសេរីភាពឈ្នះរាល់សេចក្តីភ័យខ្លាច គេប្រកាសព្រះបន្ទូលដោយចិត្តអង់អាចមោះមុត (កិច្ចការ ២:២៩,៤:១៣, ៤:២៩, ៣១) ព្រះវិញ្ញាណបានលើកទឹកចិត្តសាវ័កព្រះអង្គអោយអង់អាចក្នុងការប្រកាសដំណឹងល្អ ធ្វើអោយសត្រូវរបស់ពួកគេងឿងឆ្ងល់ថាហេតុអ្វីបានជាគេអង់អាចយ៉ាងនេះ! "គេជាមនុស្សសាមញ្ញពុំដែលរៀនសូត្រអ្វីឡើយ" (កិច្ចការ ៤:១៣)។ ពួកគេពុះពារគ្រប់ឧបសគ្គទាំងអស់ ទាំងការកើតទុក្ខ ទាំងសេចក្តីរីករាយ គ្មានអ្វីអាចបញ្ឈប់ពួកគេបានឡើយ។ ពួកសាវ័កតែងតែឆ្លើយទៅអស់អ្នកដែលរំខានពួកគេថា "យើងខ្ញុំឈប់និយាយអំពីហេតុការណ៍ដែលយើងខ្ញុំបានឃើញបានឮនោះពុំកើតទេ!" (កិច្ចការ ៤:២០)។ នេះជាសក្ខីភាពបញ្ជាក់ថាព្រះសហគមន៍កើតឡើង

យ៉ាងដូចម្ដេច ហើយចាប់ពីថ្ងៃនោះមកពួកគេនឹងមិនឈប់ប្រកាសដំណឹងល្អឡើយ។ ថ្ងៃព្រះវិញ្ញាណយាងមក "ប៉ុន្តែអ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយគឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា..." (កិច្ចការ ១:៨)

**៣. ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាទីពំនឹងរបស់ព្រះសហគមន៏និងជាទំនាក់ទំនង :**

ប្រសិនបើយើងយល់នូវបេសកកម្មរបស់ព្រះសហគមន៏ យើងត្រូវតែចូលរួមនៅកន្លែងមួយដែលក្រុមសាវ័កកំពុងរួបរួមគ្នាអធិដ្ឋាន (២៤:៤៩) អធិដ្ឋានទូលអង្វរព្រះនាងម៉ារី "ព្រះមាតា" តាមព្រះបន្ទូលសន្យា។ នេះជាសញ្ញានៃការកកើតព្រះសហគមន៏ដែលជាជីវិតនៃគ្រីស្តបរិស័ទទាំងឡាយ។ ផលផ្លែនៃកិច្ចការរបស់ក្រុមសាវ័កនិងក្រុមបំពេញបេសកកម្មទាំងឡាយវាមិនមែនមកពីភាពឈ្លាសវៃនិងប្រសិទ្ធភាពក្នុងការរៀបចំគម្រោងការ ឬរបៀបនៃការណែនាំអំពីព្រះបន្ទូលនោះទេ ប៉ុន្តែវាកើតឡើងដោយសារការអធិដ្ឋាននៃព្រះសហគមន៏ទាំងអស់ (Evageli i nuntiandi, 75)។ ទោះជាខិតខំបែបណាក៏ដោយ ដើម្បីអោយបេសកកម្មទទួលបាននូវប្រសិទ្ធភាព គឺព្រះសហគមន៏ទាំងមូលត្រូវតែរួបរួមគ្នាជាធ្លុងមួយ គឺថា "មានចិត្តថ្លើមតែមួយ" (កិច្ចការ ៤:៣២) ហើយពួកសាវ័កទាំងនោះព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំប៉័ងនិងខិតខំអធិដ្ឋាន (កិច្ចការ ២:៤២)។ អ្នកបំរើរបស់ព្រះជាម្ចាស់យ៉ូហានប៉ូលទី ២ សរសេរថា : ទោះបីចាប់ផ្តើមសកម្មភាពអ្វីក៏ដោយ បេសកកម្មរបស់ព្រះសហគមន៏ គឺជាទីសំគាល់និងរស់នៅជាសក្ខីភាពនៃពន្លឺរបស់ព្រះជាម្ចាស់ដល់អ្នកដទៃ (Redemptors Missio, 26)។ Tertullian បានប្រាប់យើងអោយដឹងនូវអ្វីដែលបានកើតឡើងក្នុងគ្រីស្តសាសនាគ្រាដំបូង ពេលដែលពួកគេបានពោរពេញដោយសេចក្តីស្រឡាញ់ក្នុងចំណោមគ្រីស្តបរិស័ទនិងគ្រីស្តបរិស័ទ "ចូរសង្កេតមើលតើពួកគេស្រឡាញ់គ្នាយ៉ាងដូចម្តេច!" (cf.A pology, 39&7)។

សរុបសេចក្តីមកដើម្បីអោយយល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់តាមរយៈព្រះគម្ពីរ ខ្ញុំអញ្ជើញអ្នកសង្កេតមើលតើព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះអំណោយទានដ៏ថ្លៃថ្លាបំផុតរបស់ព្រះជាម្ចាស់ចំពោះមនុស្សជាតិដែលជាទីសំគាល់ដ៏ខ្ពង់ខ្ពស់នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង។ សេចក្តីស្រឡាញ់ជាប្រភព "ព្រះបន្ទូលជាជីវិត" គឺថា ព្រះជាម្ចាស់សព្វព្រះហឫទ័យចំពោះស្នាព្រះហស្តរបស់ព្រះអង្គ។ "ព្រះបន្ទូលជាជីវិត" យើងបានឃើញតាមរយៈព្រះយេស៊ូគ្រីស្តនិងតាមរយៈការឈ្នះមារបិសាច ព្រមទាំងតាមរយៈអគ្គសញ្ញាសំរុះសំរួលជានាជាមួយព្រះជាម្ចាស់។ តាមរយៈសេចក្តីពិតនេះ ចូរយើងចងចាំនូវព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីរបស់ព្រះយេស៊ូជាអម្ចាស់ដែលប្រសូតពីវិញ្ញាណដ៏វិសុទ្ធ ពោរពេញដោយអត្ថន័យសំរាប់ព្រះគម្រោងការនាំ "ដំណឹងល្អទៅប្រាប់ជនក្រីក្រ រំដោះជនដែលជាប់ជាឈ្លើយ មនុស្សខ្វាក់អោយមើលឃើញ... " នេះជាព្រះអំណោយទានដែលគ្រប់គ្នាបានទទួលនៅថ្ងៃដែលព្រះវិញ្ញាណយាងមក។ ព្រះអង្គនឹងប្រទាននូវការលើកលែងទោស និងប្រទានព្រះគម្រោងការដ៏អាថិកំបាំង ដល់ព្រះសហគមន៏គ្រប់ទិសទីលើពិភពលោកដែលជាបេសកកម្មដ៏ថ្លៃថ្លាបំផុត!

យើងជាផលផ្លែនៃបេសកកម្មរបស់ព្រះសហគមន៏ក្រោមគម្រោងការ ដ៏អាថិកំបាំងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងនឹងធ្វើជាទីសំគាល់នៃសេចក្តីស្រឡាញ់របស់ព្រះបិតាតាមរយៈព្រះយេស៊ូគ្រីស្ត។ ចូរយើងចងចាំ ដ្បិតព្រះវិញ្ញាណ

ព្រះជាម្ចាស់គង់ជាមួយយើងគ្រប់ៗគ្នា ដើម្បីប្រទានព្រះអំណោយទានគ្រប់យ៉ាងតាមរយៈយុវជន ពួកគេនឹងធ្វើអោយកំរើកខ្យល់និងភ្លើងក្នុងថ្ងៃដែលព្រះវិញ្ញាណយាងមកជាថ្មីក្នុងពិភពលោកនេះ

**៥. ព្រះវិញ្ញាណដ៏វិសុទ្ធ "ជាគ្រូក្នុងជីវិត" :**

យុវជនទាំងអស់ជាទីស្រឡាញ់! ព្រះវិញ្ញាណដ៏វិសុទ្ធគង់ជាមួយ និងប្រទានអំណាចដល់ព្រះសហគមន៍ ហើយផលផ្លែនៃព្រះវិញ្ញាណនឹងពេញលេញទៅបានអាស្រ័យលើយើងត្រៀមខ្លួនរួចជាស្រេច ក្នុងការប្រើព្រះអំណោយទាននេះបង្កើតនូវអ្វីថ្មីៗគ្រប់បែបយ៉ាង។ សំរាប់ហេតុផលនេះវាសំខាន់ណាស់សំរាប់យើងម្នាក់ៗ យល់ដឹងអំពីរបៀបទំនាក់ទំនងទៅព្រះអង្គ និងបើកដួងចិត្តអោយព្រះអង្គណែនាំយើង។ ទោះជាយ៉ាងក៏ដោយត្រង់ចំណុចនេះមានចម្ងល់ជាច្រើនតែងតែចោទឡើង : តើនរណាជាព្រះវិញ្ញាណដ៏វិសុទ្ធសំរាប់ខ្ញុំ? នេះជាព្រឹត្តិការណ៍ដែលគ្រីស្តសាសនិកជាច្រើន "មិនស្គាល់"។ នេះជាអ្វីដែលជំរុញអោយយើងរៀបចំទិវាយុវជនពិភពលោក ព្រោះខ្ញុំចង់អញ្ជើញអ្នកអោយស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធកាន់តែច្បាស់ឡើងៗដោយផ្ទាល់។ ការប្រកាសជំនឿរបស់យើងគឺ "ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ជាប្រភពនៃជីវិតតាមរយៈព្រះបិតានិងបុត្រា (Nicene-Constantinopolitan Creed)។

បាទ! ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់និងព្រះបុត្រាដែលជាប្រភពនៃជីវិត ដែលធ្វើអោយយើងបានវិសុទ្ធ។ សេចក្តីសង្ឃឹមមិនធ្វើអោយយើងខកចិត្តឡើយ ព្រោះព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គមកក្នុងដួងចិត្តយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង "រ៉ូម ៥:៥"។ ទោះជាយ៉ាងណាក៏វាពុំគ្រប់គ្រាន់ទេ បើគ្រាន់តែស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធ យើងត្រូវយាងព្រះអង្គមកតម្រែតម្រង់ចិត្តយើងទុកជា "គ្រូនៅក្នុងជីវិត"។ តើនរណាណែនាំយើងអំពីអាថិកំបាំងនៃព្រះត្រៃឯក គឺមានតែព្រះវិញ្ញាណដ៏វិសុទ្ធដែលបើកចំហដួងចិត្តអោយបានពោរពេញដោយជំនឿនិងបំភ្លឺយើង។ ព្រះវិញ្ញាណបានរុញអោយទៅម្ខាង ហើយព្រះអង្គដុតយើងដោយភ្លើងនៃសេចក្តីស្រឡាញ់ ព្រមទាំងផ្តល់បេសកកម្មនៃមេត្តាករុណារបស់ព្រះអង្គ។ ខ្ញុំដឹងច្បាស់ណាស់ថា យុវជនមានសុទ្ធាដ៏ជ្រាលជ្រៅ ពោរពេញដោយសេចក្តីស្រឡាញ់ចំពោះព្រះយេស៊ូគ្រីស្ត ដោយប្រាថ្នាចង់ជួបព្រះអង្គ និងចង់សន្ទនាជាមួយព្រះអង្គផ្ទាល់។ បើនិយាយអោយជ្រៅទៅទៀតនោះ ចូរចងចាំថាព្រះវិញ្ញាណគង់ជាមួយយើង ហើយកែប្រែយើងម្នាក់ៗ អោយដូចព្រះយេស៊ូដែលត្រូវគេឆ្កាងហើយសោយទិវង្គតនិងរស់ឡើងវិញ។ ដូច្នេះ ចូរយើងទំនាក់ទំនងជាមួយព្រះវិញ្ញាណដ៏វិសុទ្ធដោយស្និទ្ធស្នាល ដើម្បីអោយយើងស្គាល់ព្រះយេស៊ូកាន់តែច្បាស់។

**៦. អគ្គសញ្ញាលាបថ្វាស និងអគ្គសញ្ញាព្រះកាយ :**

អ្នកនឹងសួរខ្លួនឯងថា តើខ្ញុំប្រគល់ខ្លួនអោយឋិតក្រោមការណែនាំពីព្រះវិញ្ញាណដ៏វិសុទ្ធនិងធ្វើអោយរីកចំរើនក្នុងជីវិតយ៉ាងដូចម្តេច? ចម្លើយឆ្លើយថា ដូចដែលអ្នកបានដឹងហើយ គឺយើងអាចធ្វើបានតាមរយៈអគ្គសញ្ញា ព្រោះថាជំនឿបានកើតនិងរីកចំរើននឹងមាំបានក្នុងជីវិតយើងតាមរយៈអគ្គសញ្ញាសំរាប់គ្រីស្តបរិស័ទ ដូចជាអគ្គសញ្ញាជ្រមុជទឹកអគ្គសញ្ញាលាបថ្វាស អគ្គសញ្ញាព្រះកាយ ដែលត្រូវតែបំពេញមិនអាចខ្វះបានឡើយ (Cf. *the Catechisim of the*

*Catholic church 1285*)។ តាមរយៈអគ្គសញ្ញាទាំងបីខាងលើ ពិតជាជំរុញអោយជីវិតយើងជាគ្រីស្តបរិស័ទបានពេញលេញនិងចៀសផុតពីការធ្វេសប្រហែសក្នុងជំនឿដូចគ្រីស្តបរិស័ទដទៃទៀតបានជួប។ ពួកគេតែងលើកឡើងអំពីព្រឹត្តិការណ៍ឬទិដ្ឋភាពដែលកន្លងផុតទៅកាលពីអតីតកាលដែលគេពុំអាចឃើញក្នុងបច្ចុប្បន្ន ដូចករណីឬសឈើដែលពុំអាចស្រូបយកជីវជាតិបានអញ្ចឹង។ វាតែងតែកើតឡើងចំពោះយុវជនទូទៅដែលពួកគេបណ្តែតបណ្តោយខ្លួនគេអោយឃ្លាតឆ្ងាយពីជំនឿបន្ទាប់ពីពួកគេបានទទួលអគ្គសញ្ញាលាបថ្ងាស។ បន្ទាប់មកគេធ្វើដូចជាយុវជនទូទៅដែលពុំធ្លាប់បានទទួលអគ្គសញ្ញាលាបថ្ងាសអញ្ចឹង។ អ្នកត្រូវដឹងថាតាមរយៈអគ្គសញ្ញាលាបថ្ងាស អគ្គសញ្ញាជ្រមុជទឹក ហើយនិងអគ្គសញ្ញាព្រះកាយ យើងនឹងបានទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។ បងប្អូនប្រុសស្រីក្នុងនាមព្រះគ្រីស្តយេស៊ូ! ជាសមាជិកព្រះសហគមន៍ត្រូវតែហ៊ានធ្វើជាទីសំគាល់នៃសេចក្តីពិត បើមានឱកាសត្រូវផ្តល់នូវការបំរើដោយរីករាយស្របតាមជំនឿរបស់ខ្លួន។ ដូច្នេះ សូមអញ្ជើញអ្នកអោយរិះគិតនូវអ្វីដែលខ្ញុំបានសរសេរទៅអ្នក។ គ្មានអ្វីក្រៅពីការទទួលអគ្គសញ្ញាលាបថ្ងាសនោះទេ ដែលជាអាហារខាងវិញ្ញាណដើម្បីរីកចំរើនខាងជំនឿ។ ចំពោះអ្នកដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបថ្ងាស ចូរចងចាំថាអ្នកបានក្លាយទៅជា "អវយវៈព្រះសហគមន៍" គឺព្រះវិញ្ញាណគង់ជាមួយ។ ចូរទទួលព្រះអំណោយទានដ៏វិសុទ្ធនេះ ដែលជាផលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ ជាទ្រព្យដ៏មានតម្លៃរបស់អ្នកក្នុងជីវិតនេះ។ ចំពោះអ្នកទទួលអគ្គសញ្ញាជ្រមុជទឹក ហើយពុំទាន់បានទទួលអគ្គសញ្ញាលាបថ្ងាសនៅឡើយនោះ ចូររៀបចំខ្លួនទទួលដើម្បីអោយបាន "ពេញលេញ" ជាគ្រីស្តបរិស័ទ (Cf. *the catachism of the Catholic Church, 1302 – 1304*)។

អគ្គសញ្ញាលាបថ្ងាសនេះផ្តល់អោយយើងនូវថាមពលពិសេស និងធ្វើជាទីសំគាល់ក្នុងការកោតសរសើរព្រះជាម្ចាស់អស់មួយជីវិតយើង (រ៉ូម ១២:១)។ មិនតែប៉ុណ្ណោះធ្វើអោយយើងបានពេញលេញក្នុងការចូលរួមជាមួយព្រះសហគមន៍ "ជាព្រះកាយព្រះគ្រីស្ត" ក្នុងឋានៈជាសមាជិកដោយរួបរួមសាមគ្គីគ្នា (១ កូរិនថូស ១២:១២-២៥)។ ដោយបណ្តោយខ្លួនអោយឋិតក្រោមឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ អ្នកទទួលអគ្គសញ្ញាជ្រមុជទឹកគ្រប់រូប នឹងទទួលព្រះអំណោយទានពិសេសក្នុងការជួយកសាងព្រះសហគមន៍ "ព្រះវិញ្ញាណបានប្រោសប្រទានអោយម្នាក់ៗ សំដែងនូវព្រះអំណោយទានដើម្បីប្រយោជន៍រួម" (១ កូរិនថុស ១២:៧) រីឯផលដែលកើតពីព្រះវិញ្ញាណ គឺសេចក្តីស្រឡាញ់ សេចក្តីអំណរ សេចក្តីសុខសាន្ត មានចិត្តអំណត់ មានចិត្តសប្បុរស មានចិត្តសន្តោសមេត្តានិងពោរពេញដោយជំនឿ (កាឡាទី ៥:២២)។ សំរាប់អ្នកទាំងឡាយណាដែលពុំទាន់បានទទួលអគ្គសញ្ញាលាបថ្ងាសនៅឡើយនោះ ខ្ញុំសូមលើកទឹកចិត្ត សូមរួតរះរៀបចំខ្លួនទទួល... តាមរយៈលោកបូជាចារ្យប្រចាំព្រះសហគមន៍ផ្ទាល់ នេះជាឱកាសដ៏ថ្លៃថ្លាដែលព្រះជាម្ចាស់ប្រោសប្រទាន។ សូមកុំខកខានអោយសោះ។

ឥឡូវនេះខ្ញុំសូមពន្យល់អំពីអគ្គសញ្ញាព្រះកាយដើម្បីជំរុញអោយជីវិតជាគ្រីស្តបរិស័ទបានរីកចំរើន យើងត្រូវការព្រះអំណោយទានតាមរយៈព្រះកាយនិងព្រះលោហិតព្រះគ្រីស្ត។ តាមពិតយើងទទួលអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបថ្ងាសតាមរយៈអគ្គសញ្ញាព្រះកាយដែរ (cf. *The Catechism of the Catholic Church, 1322, Sacramentum Caritatis, 17*) ជា "ប្រភពដ៏ខ្ពង់ខ្ពស់បំផុត" នៃជីវិតព្រះសហគមន៍។ អគ្គសញ្ញាព្រះកាយគឺជា

"ព្រះវិញ្ញាណយាងមកគង់ជាមួយយើង ដូចជាពេលយើងថ្វាយអភិបូជាយើងនឹងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែលរួមជាមួយព្រះគ្រីស្តនិងក្នុងអង្គព្រះគ្រីស្ត។ យុវជនទាំងឡាយជាទីស្រឡាញ់! ប្រសិនបើអ្នកបានទទួលព្រះកាយជាប្រចាំនោះអ្នកនឹងបានទទួលព្រះពរដែលជាប្រភពនៃជីវិតពោរពេញដោយអំណរសប្បាយស្របតាមព្រះបន្ទូល។ ស្របពេលជាមួយនោះប្រសិនបើបទពិសោធន៍ជំនឿរបស់យើងពុំទាន់រឹងមាំគ្រប់គ្រាន់ នោះព្រះវិញ្ញាណដ៏វិសុទ្ធនឹងណែនាំយើងដោយចាក់បង្ហូរព្រះវិញ្ញាណមកអោយយើងបានរឹងមាំ ដើម្បីបំពេញបេសកកម្មស្របតាមព្រះបន្ទូលព្រះយេស៊ូគ្រិស្តប្រៀនប្រដៅ។

**៧. សេចក្តីត្រូវការនិងការរៀបចំអោយមានបេសកកម្មជាបន្ទាន់មួយ :**

មានយុវជនក្មេងៗជាច្រើន បានលាតត្រដាងអំពីក្តីព្រួយបារម្ភ និងសួរនូវសំណួរអំពីអនាគតរបស់ពួកគេ។ ពួកគេតែងសួរថា "តើត្រូវធ្វើយ៉ាងដូចម្តេច បើលើពិភពលោកនេះពោរពេញដោយអំពើអយុត្តិធម៌និងទុក្ខសោកនោះ? ហេតុដូចម្តេចបានជាគេប្រព្រឹត្តអំពើហិង្សាគំនិតអាត្មានិយមដូច្នេះ? តើយើងនឹងផ្តល់និយមន័យនៃជីវិតយ៉ាងដូចម្តេច?

តើយើងអាចនាំផលផ្លែនៃព្រះវិញ្ញាណនៃ"សេចក្តីស្រលាញ់ សេចចក្តីអំណរ សន្តិភាព សេចក្តីអំណត់ សេចក្តីមេត្តា ករុណា ចិត្តទូលំទូលាយ សេចក្តីជំនឿ សុភាពរាបសា និងការចេះគ្រប់គ្រងខ្លួនឯង (no.6) ទាំងអស់នេះឋិតនៅក្នុង ពិភពលោកពោរពេញដោយភាពភ័យខ្លាចនិងភយន្តរាយ តើយើងត្រូវជួយយុវជនយ៉ាងដូចម្តេច?

ដូចអ្វីដែលបានបញ្ជាក់នៅជំពូក ១ និងជំពូក ២ ក្នុងព្រះគម្ពីរកំណើតពិភពលោក ឬតាមរយៈអគ្គសញ្ញាសំរុះសំរួលជានាជាមួយព្រះជាម្ចាស់ តើព្រះវិញ្ញាណគង់ក្នុងជីវិតមនុស្សលោកិយមែនទេ?ចូរយើងចងចាំព្រះអំណោយទានដ៏ខ្ពង់ខ្ពស់បំផុតនេះ គឺព្រះអំណោយទាននៃព្រះវិញ្ញាណតាមរយៈព្រះយេស៊ូគ្រិស្ត។ ព្រះអំណោយទាននេះគឺចាំបាច់បំផុតសំរាប់ពិភពលោកយើងនេះ ដើម្បីជាអំណរសប្បាយក្នុងការបំពេញបេសកកម្មរបស់ព្រះសហគមន៍ដែលជាទីសំគាល់មួយរបស់យុវជន ដែលបានចូលរួមក្នុងទិវាយុវជនពិភពលោក។

យុវជនទាំងឡាយជាទីស្រឡាញ់! ខ្ញុំសូមក្រើនរំលឹកនូវចំណុចគន្លឹះខ្លះៗ ជាសេចក្តីពិត។ ជាថ្មីម្តងទៀតខ្ញុំសូមបញ្ជាក់ថាមានតែគ្រីស្តបរិស័ទប៉ុណ្ណោះ ដែលអាចបំពេញនូវទំនាក់ទំនងដ៏ជិតស្និទ្ធ ល្អរវាងគ្នានឹងគ្នាបាន ហើយអាចក្លាយទៅជាមនុស្សល្អ និងចេះកែប្រែចិត្តគំនិតជា "មនុស្សដ៏វិសុទ្ធ"។ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះអង្គណែនាំយើងអោយមានទឹកចិត្តមេត្តាករុណា និងធ្វើអោយយើងចេះស្រឡាញ់អ្នកជិតខាង ដោយត្រៀមខ្លួនបំរើគេជានិច្ច។ ព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើងអោយប្រកាសដំណឹងល្អអំពីព្រះយេស៊ូសុគតនិងរស់ឡើងវិញ ព្រមទាំងណែនាំយើងអោយប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះយេស៊ូគ្រិស្ត ដើម្បីក្លាយជា "ទីសំគាល់ និងជានិមិត្តរូបនៃសេចក្តីស្រឡាញ់ដែលបានមកពីព្រះយេស៊ូគ្រិស្តជាអម្ចាស់" (*DeusCaritas Est, 33*)។ ចំពោះអ្នកដែលបណ្តោយខ្លួនអោយឋិតក្រោមការណែនាំពីព្រះវិញ្ញាណដ៏វិសុទ្ធ និងដាក់ខ្លួនបំរើកិច្ចការប្រកាសដំណឹងល្អ ដោយគ្មានលក្ខខណ្ឌ នោះគេពិតជាបានដឹងពីតួនាទីរបស់គេក្នុងឋានៈគេជាគ្រិស្តបរិស័ទ គឺការប្រកាសដំណឹងល្អទៅមនុស្សទាំងឡាយ។ ទោះជាយ៉ាងណាក៏ដោយយើងត្រូវតែចងចាំថាយើងហ្នឹងហើយជាទីសំគាល់របស់ព្រះគ្រីស្តទៅបាន ដរាបណាយើងដាក់ខ្លួនយើងអោយឋិត

ក្រោមឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ គឺជា"ភ្នាក់ងារដ៏សំខាន់នៃកិច្ចការប្រកាសដំណឹងល្អ" cf. *Evangelii Nuntiandi, 75)* និងជាភ្នាក់ងារដ៏សំខាន់ក្នុងការបន្តបេសកកម្ម (cf. *Redemptoris Missio, 21*) ។

យុវជនទាំងឡាយជាទីស្រឡាញ់! ដូចជាបុព្វការីជាទីគោរព Paul VI និងយ៉ូហាន ប៉ូល II មានប្រសាសន៍ ថាចូរប្រកាសដំណឹងល្អ ព្រមទាំងធ្វើជាទីសំគាល់នៃជំនឿ ព្រោះមានសារសំខាន់បំផុតសំរាប់គ្រីស្តបរិស័ទ និងមិនត្រូវធ្វេសប្រហែសឡើយ (cf. *Redemptoris Missio, 1*)។ ការប្រកាសដំណឹងល្អដោយប្រើសំភារៈឬរបស់មានតម្លៃទៅអូសទាញគេ ដើម្បីអោយគេមានជំនឿ សូមកុំធ្វើដូច្នេះឡើយ ប៉ុន្តែព្រះគ្រីស្តពុំដែលបង្ខិតបង្ខំនរណាម្នាក់ទេ (cf. *Evangelii Nuntiandi, 80*) ម្យ៉ាងទៀតកាលពីជាង ២០០០ ឆ្នាំកន្លងទៅ មានសាវ័ក ១២ នាក់ បានថ្វាយជីវិតទាំងស្រុងដើរតាមព្រះយេស៊ូគ្រីស្តដោយសេចក្តីស្រឡាញ់។ ចាប់តាំងពីពេលនោះមក ព្រះបន្ទូលត្រូវបានប្រកាសទៅគ្រប់ទិសទីក្នុងពិភពលោកតាមគ្រប់មធ្យោបាយតាមរយៈបុត្រធីតារបស់ព្រះអង្គ ដែលបំពេញបេសកកម្មបំរើព្រះអង្គយ៉ាងសកម្មបំផុត ។

ថ្ងៃនេះព្រះអង្គត្រូវការសាវ័កថ្មីជាច្រើនទៀតដែលមិនគិតអំពីពេលវេលាផ្ទាល់ខ្លួន ហើយហ៊ានចំណាយពេលវេលា កម្លាំងពលំ ដើម្បីបំរើព្រះអង្គ។ ព្រះអង្គត្រូវការយុវជនដែលបើកដួងចិត្តអោយសេចក្តីស្រឡាញ់របស់ព្រះអង្គគង់ក្នុងដួងចិត្តរបស់ពួកគេ ពិសេសចំពោះអស់អ្នកដែលព្រះអង្គត្រាស់ហៅអោយមកបំពេញបេសសកម្ម មានយុវជនជាច្រើនមកហើយដែលទទួលព្រះអំណោយទានជាសន្តសន្តិ ហើយនិងមានជាបន្តបន្ទាប់ទៀត។ ទោះជាយ៉ាងណាក៏ខ្ញុំសូមប្រកាសថាព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះគ្រីស្ត។ ថ្ងៃនេះសូមអញ្ជើញយុវជនអោយបំពេញបេសកកម្មប្រកាសដំណឹងល្អអំពីព្រះយេស៊ូគ្រីស្តចាប់ពីពេលនេះតទៅ។ រឿងពិបាកមួយសំរាប់មនុស្សពេញវ័យក្នុងការគិតគូរដល់យុវជនគឺ ការយល់ដឹងអំពីយុវជនមានជំនឿ ពីព្រោះពួកគេច្រើនតែបណ្តែតបណ្តោយខ្លួនទៅតាមអ្វីដែលគេចង់ធ្វើ។ អ្នកបានដឹងអំពីឧត្តមគតិល្អ ចេះភាសា មានទំនោចិត្ត ការសង្ឃឹមរង់ចាំ ហើយមានបំណងប្រាថ្នាធ្វើយ៉ាងណាអោយខ្លួនបានប្រសើរ។ ដូច្នេះក្នុងពិភពលោកដ៏ធំធេងនេះ យើងត្រូវតែរួមជាមួយយុវជនដើម្បីមានចេតនារម្មណ៍គិតអំពីការងារ ការអប់រំសេចក្តីសង្ឃឹម និងរិះគិតអំពីទុក្ខលំបាកផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយអ្នកត្រូវតែមានសេចក្តីក្លាហានដោយសន្យាជាមួយព្រះវិញ្ញាណដ៏វិសុទ្ធថា អ្នកនឹងណែនាំយុវជនម្នាក់អោយស្គាល់ព្រះគ្រីស្តតាមរបៀបដ៏ប្រសើរបំផុត គឺ "ចេះពន្យល់ទៅអ្នកទាំងឡាយណាដែលចោទសួរអ្នកនូវហេតុផលនៃសេចក្តីសង្ឃឹមរបស់អ្នក ដោយសុភាពរាបសា និងដោយយកចិត្តទុកដាក់បំផុត" (cf. *1 Pet 3:15)* ។

សម្លាញ់ទាំងអស់ជាទីស្រឡាញ់! ដើម្បីអោយកិច្ចការនេះបានសំរេចជោគជ័យ អ្នកត្រូវតែវិសុទ្ធ និងគ្រីស្តទូតយើងពុំអាចបំបែកសន្តិភាពចេញពីបេសកកម្មបានឡើយ (cf. *Redemptoris Missio, 90)*។ សូមកុំខ្លាចធ្វើអ្វីក្នុងការក្លាយទៅជាគ្រីស្តទូតដ៏វិសុទ្ធដូចជាសន្តប្រាង់ស្វ័រសាវីយេ៉ដែលធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយទៅចុងបូពាំប្រទេសដើម្បីប្រកាសដំណឹងល្អអំពីព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ ដោយឆន្ទៈមោះមុតក្នុងការនាំពន្លឺព្រះគ្រីស្តទៅបំភ្លឺពិភពលោក ដោយបង្ហាញនូវសេចក្តីស្រឡាញ់ លុបបំបាត់នូវសេចក្តីស្អប់ខ្ពើម និងការមិនយកចិត្តទុកដាក់ចំពោះជីវិត។

### ៨. ព្រះវិញ្ញាណយាងមកក្នុងពិភពលោក :

កូន១យុវជនជាទីស្រឡាញ់! ខ្ញុំសង្ឃឹមថានឹងឃើញកូន១ជាច្រើននាក់ក្នុងខែកក្កដា ២០០៨ នៅទីក្រុងស៊ីដនី ព្រោះនេះជាឱកាសពិសេសដើម្បីទទួលបទពិសោធន៍ដែលជាអំណាចនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ សូមអញ្ជើញមកអោយបានច្រើន រួមគ្នាជាសញ្ញានៃសេចក្ដីសង្ឃឹមនិងអំណរសប្បាយក្នុងការជួយព្រះសហគមន៍ដែលរៀបចំស្វាគមន៍គ្នាទៅវិញទៅមកនៅអូស្ត្រាលី។ សំរាប់យុវជនក្នុងប្រទេសអូស្ត្រាលី គេរង់ចាំអ្នករាល់គ្នា វាជាឱកាសមាសក្នុងកាប្រកាសព្រះបន្ទូលដែលជាអំណរសប្បាយរបស់អ្នករាល់គ្នានៅទីនោះ តាមរបៀបវប្បធម៌របស់ខ្លួន។ អូស្ត្រាលីក៏មិនខុសពីប្រទេសដទៃទៀតក្នុងទ្វីបអូស៊ីអានីដែរ គេត្រូវការរកអោយឃើញនូវអ្វីដែលជាប្រភពនៃជីវិតគ្រីស្តបរិស័ទ។ សម្ដេចប៉ាបយ៉ូហានប៉ូលទី២ បានសរសេរនៅក្នុង Post-Synodal Apostolic Exhortation *Ecllesia in Oceania,* ថា "ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះសហគមន៍នៅអូសេអានីបានរៀបចំប្រកាសដំណឹងល្អដល់មនុស្សដែលកំពុងរង់ចាំព្រះគ្រីស្ត...។ ការប្រកាសដំណឹងល្អគឺជាអទិភាពចម្បងរបស់ព្រះសហគមន៍នៅអូសេអានី" (no.18)។ ខ្ញុំសូមអញ្ជើញអ្នកផ្ដល់ពេលវេលាសំរាប់អធិដ្ឋានអស់ពីដួងចិត្តក្នុងទិវាយុវជនពិភពលោកលើកទី XXIII។ ដូច្នេះនៅក្នុងស៊ីដនីអ្នកនឹងនឹកឃើញឡើងវិញនូវអ្វីដែលអ្នកបានសច្ចាប្រណិធានក្នុងឱកាសបានទទួលអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបថ្ងាស។ចូរយើងរួបរួមគ្នាអធិដ្ឋានទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធនូវព្រះអំណោយទានសំរាប់ព្រះសហគមន៍យើងម្នាក់១ និងសំរាប់មនុស្សទាំងឡាយក្នុងថ្ងៃព្រះវិញ្ញាណយាងមកជាថ្មីនៃសហសវត្សរ៍ទី ៣ របស់ព្រះសហគមន៍យើង។ សូមព្រះមាតាម៉ារីនិងសាវ័ករបស់ព្រះយេស៊ូគ្រីស្ត រួមជាមួយអ្នករាល់គ្នា ជួយអង្វរព្រះជាម្ចាស់ អោយចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធលើយុវជនទាំងអស់ ដើម្បីអោយពួកគេបានលាងជំរះចិត្តគំនិតអោយបានស្អាតហ្មត់ហ្មង។ ចូរចងចាំថាព្រះសហគមន៍មានទំនុកចិត្តលើអ្នក! យើងជាគង្វាលតែងតែអធិដ្ឋានជាពិសេសសំរាប់អ្នក ដើម្បីអោយអ្នកចេះស្រឡាញ់ និងដឹកនាំយុវជនដទៃទៀតអោយស្រឡាញ់ព្រះយេស៊ូគ្រីស្តកាន់តែខ្លាំងឡើង១ ហើយផ្ញើជីវិតទាំងស្រុងលើព្រះអង្គផង។

ខ្ញុំសូមទូលអង្វរព្រះជាម្ចាស់ ប្រោសប្រទានពរដល់អ្នកអោយបានពោរពេញដោយសេចក្ដីស្រឡាញ់។

*From Lorenzago, 20 July 2007*

**BENEDICTUS PP. XVI**